ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៣-០៧-២០០៩ ដោយមានសមាសភាព ដូចខាងក្រោម:

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក[redacted]

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៧៥៥ ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០០៦ ដែលមាន:

- **ជនជាប់ចោទឈ្មោះ**[redacted]ម៉ៅ ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើត និងរស់នៅភូមិគូលែន [redacted] ស្រុកគូលែន ខេត្តព្រះវិហារ ឪពុកឈ្មោះ ហួន ធូន (រ) ម្តាយឈ្មោះ ឆាត់ ផើង (រ) នៅលីវ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី ០៦-១១-២០០៥ ឃុំខ្លួនថ្ងៃទី ១០-១១-២០០៥។

មានលោក[redacted]ហេង ជាមេធាវីការពារ ។

<u>ត្រូវជាប់ចោទពីបទ:</u> រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិឈូក ឃុំភ្នំត្បែង២ ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី ០៥-១១-២០០៥ តាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**[redacted]សុផល ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted] ស្រុកគូលែន ខេត្តព្រះវិហារ ត្រូវជាបងថ្លៃកុមារីរងគ្រោះឈ្មោ[redacted]ខ្លា អាយុ ១៣ឆ្នាំ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ[redacted] ម៉ៅ ប្តឹងមិនសុខចិត្ត និងសាលក្រមព្រហ្មទណ្ឌលេខ ០៩ (គ) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។ ឡ

## ឯដំណើររឿងមានដូចតទៅ:

តាមកំណត់ហេតុបណ្តឹង ចុះថ្ងៃទី ០៦-១១-២០០៥ របស់ឈ្មោះ [redacted] សុផល ថា កាលពីថ្ងៃទី ០៥-១១-២០០៥ វេលាម៉ោង ២រសៀល ប្អូនស្រីខ្លួនឈ្មោះ [redacted] ខ្នា បានដើមពីចំការដីក្រហម ពីរនាក់ក្មេងប្រុសឈ្មោះ [redacted] ភួង ពេលធ្វើដំណើរដល់ព្រៃខាងត្បូងអូររំចេក ស្រាប់តែឈ្មោះ [redacted] ម៉ៅ បានចាប់ប្អូនស្រី [redacted] ខ្នា រំលោភពិតប្រាកដ ។

**- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៩ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តព្រះវិហារ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ០៦-១១-២០០៥ ពីបទ រំលោភសេពសន្ថវ: ប្រព្រឹត្តនៅភូមិឈូក ឃុំភ្នំត្បែង២ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី ០៥-១១-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៥ ចំណុច ២ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៅ សងប្រាក់ជម្ងឺចិត្ត កិត្តិយស សេចក្តីថ្លៃថ្នូរ និងប្រាក់សោហ៊ុយលើការចំណាយផ្សេងៗ ចំនួន ៦.០០០.០០០រៀល ( ប្រាំមួយលានរៀល) តាមពាក្យប្តឹងសុំ ។

បើឈ្មោះ [redacted] ម៉ៅ គ្មានប្រាក់បង់ បង្គាប់ឱ្យដាក់គុកបង្ខំរូបរាងកាយដើម្បីទារប្រាក់ធនទណ្ឌ តាមមាត្រា ៣ និងមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណ: ចំពោះមុខគូក្តី ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍រយ:ពេល ២ខែ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ ( ត) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តព្រះវិហារ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ឆ្លើយនៅសាលាដំបូងខេត្តព្រះវិហារ ។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល ឆ្លើយនៅសាលាដំបូងខេត្តព្រះវិហារ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨-០៨-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ សាលាឧទ្ធរណ៍អាចលើកមកជំនុំជម្រះបាន ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៨-០៨-២០០៦ របស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៅ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ ចុះថ្ងៃទី ១៧-០៧-២០០៦ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការ តែលុបចោលវិធានអនុវត្តដាក់គុកបង្ខំរូបរាងកាយ ចេញពីការប្រកាសនៃសាលក្រម ក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ ។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ២០១4

ក្រឡាបញ្ជី

[redacted]